**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

លេខ: ២៨៧ គ.ជ.ប.ស.ស.រ

# សេចក្តីសម្រេច

## ស្តីពី

## ការព្យួរសិទ្ធិបោះឆ្នោតជាបណ្តោះអាសន្ន ប្រធាន អនុប្រធាន និងសមាជិក គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃអាទិត្យ ទី២៣ ខែកក្កដា ឆ្នាំ២០២៣

## គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៥/០០២ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៥/០០៣ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៧/០១០ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៥/៣២៧ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៥ ស្តីពីការតែងតាំងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៧/១១៦៩ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីការតែងតាំងអនុប្រធាន និងសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ជំនួសអនុប្រធាន និងសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដែលបានលាឈប់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦២១/៩៩១ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២១ ស្តីពីការតែងតាំងប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ជំនួសប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដែលបានលាឈប់
- បានឃើញសេចក្តីសម្រេចលេខ ០៤៤ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២១ ស្តីពីការប្រកាសឱ្យប្រើបទបញ្ជាផ្ទៃក្នុងរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញសេចក្តីសម្រេចលេខ ៤៣៣ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២២ ស្តីពីការដាក់ឱ្យប្រើបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣
- យោងស្មារតីអង្គប្រជុំគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ថ្ងៃទី ៨ ខែមិថុនា ឆ្នាំ២០២៣

## សម្រេច

**ប្រការ១.-**

ព្យួរសិទ្ធិបោះឆ្នោតជាបណ្តោះអាសន្ន ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃអាទិត្យ ទី២៣ ខែកក្កដា ឆ្នាំ២០២៣ ដូចខាងក្រោម ៖



វិថីរដ្ឋសភា សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
St., Ratsaphea Tonle Basac, Khan Chamkar Mon, Phnom Penh, Cambodia
ទូរស័ព្ទ : 023 235 271
អ៊ីមែល : info@nec.gov.kh

| ល.រ | នាមត្រកូល និងនាមខ្លួន | ភេទ | ថ្ងៃខែឆ្នាំកំណើត | លេខកូដការិយាល័យ | ឃុំ សង្កាត់ | រាជធានី ខេត្ត |
|---|---|---|---|---|---|---|
| ១ | **ប្រាជ្ញ ចន្ទ** | ប្រុស | ០១-០៤-១៩៥៧ | ០៨០០ | កោងកាង | ត្បូងឃ្មុំ |
| ២ | **នុត សុខុម** | ប្រុស | ២១-០៧-១៩៥៥ | ០៦៣៩ | ស្វាយ | កំពង់ឆ្នាំង |
| ៣ | **មាន សតិ** | ប្រុស | ១១-០៥-១៩៥២ | ០៤៩៣ | ទឹកល្អក់ទី១ | ភ្នំពេញ |
| ៤ | **ឌីម សុវណ្ណារុំ** | ប្រុស | ១៥-០៣-១៩៧៣ | ១១៩៨ | ច្រាំងចំរេះទី១ | ភ្នំពេញ |
| ៥ | **ឌុច សុន** | ប្រុស | ០១-០១-១៩៥៥ | ០៩១៤ | បឹងទំពន់ទី១ | ភ្នំពេញ |
| ៦ | **ហ៊ីង ធីរឫទ្ធិ** | ប្រុស | ២៦-០៨-១៩៦៦ | ០៥៣១ | ទឹកល្អក់ទី៣ | ភ្នំពេញ |
| ៧ | **ឯម សូផាត** | ប្រុស | ១៨-០៤-១៩៥៧ | ០៥៥៩ | បឹងកក់ទី១ | ភ្នំពេញ |
| ៨ | **ហ៊ែល សារ៉ាត់** | ប្រុស | ១៥-១១-១៩៧៩ | ២០៤៥ | ព្រែកលៀប | ភ្នំពេញ |
| ៩ | **មាន្ស ពុទ្ធា** | ប្រុស | ២៩-០៤-១៩៦៥ | ០០៧១ | បឹងកេងកងទី៣ | ភ្នំពេញ |

**ប្រការ២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៣.-**

សាមីខ្លួនដូចមានចែងក្នុងប្រការ ១ អគ្គលេខាធិការ គ.ជ.ប និងប្រធានគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ៩ រោច ខែជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១២ ខែមិថុនា ឆ្នាំ២០២៣

**ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រធាន**

**ប្រាជ្ញ ចន្ទ**

**__ចម្លងទូលថ្វាយ__ ៖**

- ព្រះមហាក្សត្រ

**__ចម្លងជូន__ ៖**

- ក្រុមប្រឹក្សាធម្មនុញ្ញ
- ព្រឹទ្ធសភា
- រដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី

"__ដើម្បីជូនជ្រាប__"

- ដូចប្រការ ៣

" __ដើម្បីអនុវត្ត__ "

- ឯកសារ-កាលប្បវត្តិ